ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែសីហា ឆ្នាំ២០១៨

នៅក្នុងខែសីហា ឆ្នាំ២០១៨នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ:

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖**

-អនុញ្ញាតឱ្យឯកឧត្តម Prasith SAYASITH ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា

-អនុញ្ញាតឱ្យឯកឧត្តម Stepan ZHIRYAKOV អនុប្រធានគណៈកម្មាធិការកសិកម្ម គោលនយោបាយស្បៀងអាហារ និងការគ្រប់គ្រងបរិស្ថាន នៃក្រុមប្រឹក្សាសហព័ន្ធ នៃសភាសហព័ន្ធ នៃសហព័ន្ធរុស្ស៊ី ចូលជួបសម្តែងការគួរសម

-អនុញ្ញាតឱ្យក្រុមអ្នកសង្កេតការណ៍អន្តរជាតិចំនួន៣៧រូប មកពី១៤អង្គការអន្តរជាតិ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ

-អញ្ជើញដឹកនាំអង្គប្រជុំស្តីពី ការត្រៀមរៀបចំបុណ្យខួបលើកទី៤០ឆ្នាំ ទិវាជ័យជម្នះ ៧មករា

-អញ្ជើញចូលរួមក្នុងពិធីប្រកួតកីឡាវាយកូនគោលផ្នែកនារី Cambodia golf & country club ដើម្បីជាការលើកទឹកចិត្តចំពោះវិស័យកីឡាវាយកូនគោលផ្នែកនារី ស្ថិតនៅឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

-អញ្ជើញចុះពិនិត្យស្ថានភាពទឹកជំនន់ស្ទឹងព្រែកត្នោត ដែលកំពុងគំរាមកំហែងកាន់តែខ្លាំងដល់ប្រជាពលរដ្ឋរស់នៅក្នុងភូមិសាស្ត្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាគោរពវិញ្ញាណក្ខន្ធ និងអញ្ជើញជាអធិបតីប្រទានភ្លើងបូជាសពឯកឧត្តម **ស ថេង** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-អញ្ជើញប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសល ជូនដល់ដួងវិញ្ញាណក្ខន្ធបុព្វការីជន និងញាតិកាទាំង៧សណ្តានរបស់សម្តេច នៅឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៩ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៣ច្បាប់ ។

**១.២.ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា ប្បាន :**

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ និងជ្រាបជាព័ត៌មានចំនួន២៧ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា ប្បាន :**

-អនុញ្ញាតឱ្យលោក Etienne FRANK ប្រធានក្រុមហ៊ុន ZETA Espace Antibes Route De Grasse និងសហការី ដែលមកពីប្រទេសបារាំង ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ

-អនុញ្ញាតឱ្យក្រុមការងារគណៈប្រតិភូព្រឹទ្ធសភា ចូលរាយការណ៍ពីការងារមួយចំនួនដែលត្រូវត្រៀមទៅចូលរួមប្រជុំមហាសន្និបាតអន្តរសភាអាស៊ាន (AIPA)លើកទី៣៩ នៅសាធារណរដ្ឋសិង្ហបុរី

-អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត មកពីប្រទេសបារាំងទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្តាល

-អញ្ជើញចូលរួមក្នុងវេទិកាពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងគណបក្សនយោបាយទាំង២០ដែលបានចូលរួមការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញចូលរួមក្នុងពិធីបុណ្យសពឯកឧត្តម ***ស ថេង*** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៤៥ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៥ច្បាប់ ។

**២.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា :**

ក្នុងខែសីហានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម:

**២.១. មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន០២ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន០៥ករណី និងទទួលពាក្យបណ្តឹងពីក្រសួង ស្ថាប័នដែលចំលងជូនមកព្រឹទ្ធសភាជ្រាបចំនួន១០ករណី

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានប្រជុំពិភាក្សាលើសេចក្តីព្រាងកម្មវិធីចុះបេសកកម្មសិក្សាស្រាវជ្រាវប្រមូលព័ត៌មានជាមួយថ្នាក់ដឹកនាំស្រុក និងអាជ្ញាធរមូលដ្ឋានក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ

-អញ្ជើញចូលរួមប្រជុំដើម្បីពិនិត្យ និងពិភាក្សាអំពីការត្រៀមរៀបចំពិធីធ្វើបទបង្ហាញអំពីលទ្ធផលនៃការចូលរួមមហាសន្និបាតពេញអង្គលើកទី២៤ នៃសភាAPF នៅសភាកេបិច ប្រទេសកាណាដា

-អញ្ជើញចូលរួមប្រជុំពិភាក្សាការងារ ដើម្បីពិនិត្យលើខ្លឹមសារត្រៀមចូលរួមមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៣ នៅប្រទេសសិង្ហបុរី

-អញ្ជើញចូលរួមប្រជុំ ដើម្បីផ្សព្វផ្សាយសេចក្តីសម្រេចចាត់តាំងក្រុមសមាជិកព្រឹទ្ធសភា និងចាត់តាំងភារកិច្ចរបស់ក្រុមសមាជិកព្រឹទ្ធសភា ទទួលបន្ទុកសហប្រតិបត្តិការជាមួយអន្តរសភាកម្ពុជា-ឡាវ-វៀតណាម

-អញ្ជើញចូលរួមប្រជុំពិភាក្សាស្តីពី គម្រោងថវិកាឆ្នាំ២០១៩របស់ព្រឹទ្ធសភា

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះទៅតាមបណ្តាខេត្ត ក្រុង រាជធានីភ្នំពេញចំនួន១៩៦លើក ដើម្បីជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៧៧លើក ។

**៣. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** អញ្ជើញទៅចូលរួមពិធីសំណេះសំណាល និងសួរសុខទុក្ខពាណិជ្ជករជនជាតិខ្មែរចំនួន១០០នាក់ នៅទីក្រុង Oakland រដ្ឋកាលីហ្វូនីញ៉ា សហរដ្ឋអាមេរិក

-ឯកឧត្តម **ប្រាក់ ចំរើន** និងឯកឧត្តម **ទេព យុទ្ធី** អញ្ជើញចូលរួមវេទិកាសភាតំបន់អាស៊ី-ប៉ាស៊ីហ្វិចលើកទី៤ ស្តីពីសុខភាពពិភពលោក នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន

-ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ឯកឧត្តម **ជុំ វង់** និងលោកជំទាវ **មុំ សណ្តាប់** អញ្ជើញទទួលជួបសវនាការ និងពិភាក្សាការងារជាមួយនឹងគណៈប្រតិភូក្រុមប្រឹក្សាសហព័ន្ធ នៃសភាសហព័ន្ធនៃសហព័ន្ធរុស្ស៊ី ដឹកនាំដោយឯកឧត្តម Stepen Zhiryakov អនុប្រធាន

គណៈកម្មាធិការកសិកម្មគោលនយោបាយស្បៀងអាហារ និងការគ្រប់គ្រងបរិស្ថាន នៃក្រុមប្រឹក្សាសហព័ន្ធ នៃសភាសហព័ន្ធនៃសហព័ន្ធរុស្ស៊ី និងជាប្រធានក្រុមមិត្តភាពសភារុស្ស៊ីជាមួយព្រឹទ្ធសភាកម្ពុជា

-ឯកឧត្តម **ជា ជេដ្ឋ** អនុញ្ញាតឲ្យលោក Hakan Atasever នាយកប្រតិបត្តិវិទ្យាស្ថានសន្ទនាមេគង្គ(MDI) និងសហការី ចូលជួបសម្តែងការគួរសម និងថ្លែងអំណរគុណចំពោះលទ្ធផលនៃកិច្ចសហប្រតិបត្តិការរវាងក្រុមមិត្តភាពព្រឹទ្ធសភាកម្ពុជាជាមួយសភាតួកគី

-ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** អញ្ជើញទទួលជួប និងធ្វើបទសម្ភាសន៍ជាមួយលោកប្រធានទូរទស្សន៍ NHK JAPAN ដើម្បីស្វែងរកឱកាសបណ្តាក់ទុនវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា និងជួបលោក Yamamoto ដែលបានដឹកនាំអ្នកវិនិយោគទុនមកពីប្រទេសជប៉ុនចំនួន០៥នាក់ ចុះពិនិត្យមើលនៅលើទីតាំងជាក់ស្តែងដើម្បីស្វែងរកឱកាសវិនិយោគនៅលើដីឫទ្ធី សែនជី ។ ៣

ថ្ងៃ ចន្ទ ១កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០១៨

**ជ.ប្រធានព្រឹទ្ធសភា**
**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសា